ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

លេខ:...២៥១...សហវ.ពដ.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០០១

# ប្រកាស

ស្តីពី

ការណែនាំអនុវត្តអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១
ស្តីពីការធ្វើវិសោធនកម្មលើមាត្រា ៣១ នៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែមលេខ ១១៤ អនក្រ.បក
ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត-១១៩៨-៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២-នស-៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស-រកម-០១៩៦-១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ នស-រកម-០២៩៧-០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម លេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១ស្តីពីការធ្វើវិសោធនកម្មលើមាត្រា ៣១ នៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែមលេខ ១១៤ អនក្រ.បកចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩
- យោងតាមការចាំបាច់នៃការងារគ្រប់គ្រងប្រមូលពន្ធរបស់នាយកដ្ឋានពន្ធដារ ។

# សម្រេច

**ប្រការ ១.-**

អនុវត្តតាមមាត្រាទី០១ នៃអនុក្រឹត្យ លេខ ១៥ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១ ស្តីពីការធ្វើវិសោធនកម្មលើមាត្រា ៣១ នៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែមលេខ ១១៤ អនក្រ.បកចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ វៀរលែងតែចំពោះក្រុមហ៊ុនដែលមានអាជីវកម្មជាអ្នកផ្គត់ផ្គង់ប្រេងឥន្ធនៈ អាករលើធាតុចូលលើការនាំចូលឬការទិញ ប្រេងសាំងស៊ុបពែរ ប្រេងសាំងធម្មតា ប្រេងម៉ាស៊ូត និង ប្រេងរំអិល ទោះបីសម្រាប់ប្រើប្រាស់ក្នុងអាជីវកម្មរបស់សហគ្រាសក្តី មិនត្រូវបានអនុញ្ញាតជាឥណទានអាករលើធាតុចូលទេ ។

**ប្រការ ២.-**

បទប្បញ្ញត្តិនៃប្រការ១ ខាងលើនេះ ត្រូវអនុវត្តចំពោះ ការនាំចូល ឬការទិញ ដែលបានធ្វើឡើងនៅចំ ឬក្រោយថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១ ។

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤.-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងគ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត-ក្រុង
  "ដើម្បីជូនជ្រាបជាពត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីមុខការ"
- គ្រប់អង្គភាពពន្ធដារ
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ ។